**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**រាជរដ្ឋាភិបាលកម្ពុជា**

**ក្រសួងមហាផ្ទៃ**

លេខ :...០៨១...សប្រក

# សេចក្តីប្រកាសព័ត៌មាន

## ស្តីពី ផលប៉ះពាល់តំបន់ និងជនស៊ីវិលកម្ពុជា ដោយអំពើឈ្លានពានរបស់ភាគីថៃ លើដែនអធិបតេយ្យកម្ពុជា ពីម៉ោង៦ល្ងាច ថ្ងៃទី២៦ ខែធ្នូ ដល់ម៉ោង៧ព្រឹក ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥

គិតចាប់ពីម៉ោង៦ល្ងាច ថ្ងៃទី២៦ ខែធ្នូ រហូតដល់ម៉ោង៧ព្រឹក ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥នេះ អំពើឈ្លានពានរបស់រដ្ឋាភិបាល និងយោធាថៃ ជាពិសេសការផ្ដោង និងទម្លាក់គ្រាប់គ្រប់ប្រភេទ គ្រប់ទម្រង់ ចូលតំបន់ស៊ីវិល បានបណ្តាលឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដូចខាងក្រោម៖

**១-ករណីពលរដ្ឋស្លាប់ និងរបួសថ្មី៖** គ្មាន។ គិតសរុបពីថ្ងៃទី៧ ខែធ្នូ មកដល់ពេលនេះ មានពលរដ្ឋស្លាប់ចំនួន៣១នាក់ និងរបួសចំនួន៩១នាក់។

**២-ករណីពលរដ្ឋនៅជំរំភៀសសឹក៖** គិតសរុបពីថ្ងៃទី៧ ខែធ្នូមក មានជនភៀសសឹកសរុប **៦៣៤.៤២០នាក់** ក្នុងនោះស្ត្រី **៣៣១.១៣៩នាក់** និងកុមារ**២០១.១៥៩នាក់**។ តួលេខនេះ អាចមានការប្រែប្រួលជាបន្តបន្ទាប់ទៀត។

**៣-ករណីបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធរូបវន្តស៊ីវិលថ្មី៖** គ្មាន។ គិតសរុបពីថ្ងៃទី៧ ខែធ្នូមក **ការខូចខាតទ្រព្យសម្បត្តិឯកជន** រួមមាន ផ្ទះ១៥០ខ្នង អគារឯកជន៦ អគារស្នាក់នៅ/សណ្ឋាគារ៥ ស្ថានីយ៍ប្រេង១ រថយន្ត២៨គ្រឿង ម៉ូតូ១គ្រឿង លានទិញដំឡូង១ អគារឃ្លាំងទំនិញ១ បង្គោលអង់តែនទូរសព្ទ២ ជង្រុកស្រូវ១ និងសត្វពាហនៈ១។ **ការខូចខាតទ្រព្យសម្បត្តិសាធារណៈ** រួមមាន សាលារៀន៦ មណ្ឌលសុខភាព២ សំណង់អគារ១៤ វត្តអារាម៥ សាលាឆទាន១ រថយន្ត១គ្រឿង ប្រាសាទបុរាណមួយចំនួន ស្ពាន៥ ផ្សារ១ ផ្លូវចំនួន៣ និងប្រព័ន្ធផ្គត់ផ្គង់អគ្គិសនី១។ ពេលនេះ មានពលរដ្ឋខ្មែរជាង៦០ម៉ឺននាក់ រួមមានស្ត្រីជាង៥០% និងកុមារជាង៣០% កំពុងរងទុក្ខ បន្ទាប់ពីបង្ខំចិត្តភៀសសឹក គេចគ្រាប់កាំភ្លើង គ្រាប់ផ្លោង និងគ្រាប់ទម្លាក់ពីយន្តហោះចម្បាំង។

ដូចគោលជំហរតាំងពីដើមមករបស់រាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា **ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** មានអំណរសាទរយ៉ាងក្រៃលែង ចំពោះលទ្ធផលកិច្ចប្រជុំពិសេសលើកទី៣ របស់គណៈកម្មាធិការព្រំដែនទូទៅ កម្ពុជា-ថៃ (GBC) ថ្ងៃទី២៧ ខែធ្នូនេះ ក្រោមការសង្កេតការណ៍ពីក្រុមអ្នកសង្កេតការណ៍អាស៊ាន (AOT) ដែលបានអនុម័ត និងចុះហត្ថលេខាលើសេចក្តីប្រកាសរួម បញ្ជាក់ពីការប្តេជ្ញាចិត្តយ៉ាងម៉ឺងម៉ាត់ អនុវត្តបទឈប់បាញ់ឱ្យបានពេញលេញ និងស្វែងរកសន្តិភាព ស្ថិរភាព និងសុវត្ថិភាពជូនប្រជាពលរដ្ឋទាំងសងខាង។ លទ្ធផលនេះ ក៏ធ្វើឱ្យយើងមើលឃើញកាន់តែច្បាស់ពីគុណតម្លៃ នៃការជួយជ្រោមជ្រែងរបស់មិត្តភក្តិបរទេស មិត្តអាស៊ាន និងសហគមន៍អន្តរជាតិ ជាពិសេសសហរដ្ឋអាម៉េរិក សាធារណរដ្ឋប្រជាមានិតចិន និងប្រទេសម៉ាឡេស៊ី ដើម្បីនាំមកនូវកម្មវត្ថុរួម គឺ**សន្តិភាព និងស្ថិរភាពសម្រាប់ប្រជាជនកម្ពុជា** ប្រជាជនក្នុងតំបន់ និងពិភពលោក។

តាមស្មារតីនេះ **ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** ទទូចដល់ភាគីថៃគ្រប់មជ្ឈដ្ឋាន បញ្ឈប់ជាបន្ទាន់ ការផលិតមាតិកា ឬការបង្កើតព័ត៌មានក្លែងក្លាយ បំផុសបំផុល និងបំភ្លៃការពិត ដោយរួមគ្នាបង្កបរិយាកាសអំណោយផលដល់ការអនុវត្តបទឈប់បាញ់ និងការចរចាជាបន្តបន្ទាប់។

រហូតមកដល់ថ្ងៃនេះ ក្រោមយុទ្ធសាស្ត្រការពារជាតិ **សម្តេចតេជោ ហ៊ុន សែន** និង **សម្តេចធិបតី ហ៊ុន ម៉ាណែត** កម្លាំងវីរយុទ្ធជនកម្ពុជា បានតស៊ូប្រយុទ្ធការពារបូរណភាពទឹកដីប្រកបដោយភាពអង់អាចជាញជ័យ ទន្ទឹមគ្នានឹងកម្លាំងមហាសាមគ្គីជាតិខ្មែរក៏កាន់តែរឹងមាំខ្ពស់ត្រដែត ដោយកូនខ្មែរគ្រប់រូបបានរំលេចស្មារតីរួបរួមជាធ្លុងមួយ រួមចំណែកសម្រាលបន្ទុកការលំបាករបស់ពលរដ្ឋភៀសសឹក។ **ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** មានមោទនភាព សូមកត់ត្រាទុករបត់ប្រវត្តិសាស្ត្រមួយនេះ និងសូមអំពាវនាវឱ្យកូនខ្មែរបន្តថែរក្សាស្មារតីជាតិមួយនេះ ឱ្យបានឋិតថេរជានិរន្តរ៍។

ថ្ងៃសៅរ៍ ៨កើត ខែបុស្ស ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០២៥